TOILET BOARD COALITION

របាយការណ៍ប្រចាំឆ្នាំ 2025



# ការជំរុញដំណោះស្រាយអាជីវកម្ម ដើម្បីដោះស្រាយវិបត្តិអនាម័យ

www.toiletboard.org

# សារពីថ្នាក់ដឹកនាំស្ថាប័ន

ឆ្នាំនេះគឺជាគម្រប់ខួបមួយទសវត្សរ៍នៃការពន្លឿនដំណោះស្រាយអាជីវកម្ម ដើម្បីដោះស្រាយវិបត្តិអនាម័យ។ ក្នុងរយៈពេលដប់ឆ្នាំកន្លងមក យើងបានគាំទ្រសហគ្រាសតូចមធ្យមដែលមានភាពច្នៃប្រឌិត នៅក្នុងវិស័យសេដ្ឋកិច្ចអនាម័យក្នុងតំបន់អាស៊ី អាហ្វ្រិក និងអាមេរិកឡាទីន ដោយផ្តល់កម្មវិធីរបស់យើងជាបួនភាសាគឺ ភាសាអង់គ្លេស ភាសាបារាំង ភាសាអេស្ប៉ាញ និងភាសាខ្មែរ។

នៅឆ្នាំ 2025 យើងមានមោទនភាពយ៉ាងខ្លាំងក្នុងការបញ្ចប់វគ្គសម្រាប់សហគ្រាសតូច និងមធ្យម ចំនួន 23 ពីជុំវិញពិភពលោក ជាមួយនឹងការគាំទ្រពីអ្នកជំនាញមកពីក្រុមហ៊ុនសាជីវកម្មដូចជា Unilever, LIXIL និង Kimberly-Clark ចំនួន 25នាក់ ដែលបានណែនាំ និងគាំទ្រការអភិវឌ្ឍអាជីវកម្មរបស់ពួកគេពេញមួយឆ្នាំ។ ឆ្នាំនេះ គឺជាពេលវេលាមួយសំខាន់ផងដែរ ព្រោះយើងបានពង្រីកប្រតិបត្តិការរបស់យើងទៅកាន់ប្រទេសកម្ពុជា ជាមួយនឹងការគាំទ្រពី ធនាគារអភិវឌ្ឍន៍អាស៊ី។

រហូតមកដល់បច្ចុប្បន្ន មានសហគ្រាសតូច និងមធ្យម ចំនួន 111 បានបញ្ចប់វគ្គនៃ កម្មវិធីពន្លឿនអាជីវកម្មរបស់យើង ហើយទាំងអស់នេះ ធ្វើអោយយើងសម្រេចបាន ការផ្តល់ផលជះជាវិជ្ជមានដល់មនុស្ស ចំនួន 13 លាននាក់ និងបានជួយកៀរគរការវិនិយោគ ចំនួន 49 លានដូល្លារអាមេរិក។ លទ្ធផលទាំអនេះ អាចសម្រេចទៅបានដោយសារតែមានការជំរុញ ពីសំណាក់សមាជិកស្ថាបនិករបស់យើង រួមមាន Unilever, LIXIL និង Kimberly-Clark ព្រមទាំងអ្នករួមចំណែក និងដៃគូសំខាន់ៗដូចជា Aqua for All, ធនាគារអភិវឌ្ឍន៍អាស៊ី, IDB, IDB Lab, Source of Innovation, Water For People និងស្ថាប័នផ្សេងៗទៀត។

យើងដឹងថាការសហការជាមួយគ្នានាំមកនូវប្រសិទ្ធភាពការងារ។ នៅពេលដែលផ្នែកទាំងអស់នៃសង្គមរួមធ្វើការសហការជាមួយគ្នា យើងអាចសម្រេចបាននូវគោលអភិវឌ្ឍន៍ប្រកបដោយចីរភាព6 (SDG 6) ពោលគឺការសម្រេចបាននូវសុវត្ថិភាពអនាម័យសម្រាប់មនុស្សគ្រប់គ្នា និងបើកផ្លូវឱ្យកំណើននៃភាពរីកចម្រើនទៅលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀតទាំងអស់។

អនាគតនៃវិស័យអនាម័យស្ថិតនៅទីនេះ ហើយយើងកំពុងបង្កើនល្បឿនឲ្យវាកាន់តែខ្លាំង។

សូមអរគុណដែលបានក្លាយជាផ្នែកមួយនៃការធ្វើដំណើរនេះ។





**Greg Davies**

CEO TOILET BOARD COALITION

# ផលជះវិជ្ជមាន មកទល់ពេលបច្ចុប្បន្ន

**111** ក្រុមហ៊ុន ដែលបានបញ្ចប់វគ្គ

ជីវិតមនុស្សចំនួន **13M** ទទួលរងផលជះវិជ្ជមាន

**$49M** នៃការវិនិយោគដែលបានកៀរគរដល់សហគ្រាសដែលចូលរួមកម្មវិធី

©AKAMU ECOSAN

TOILET BOARD COALITION

# អ្នកណែនាំ អាជីវកម្ម

Unilever
LIXIL
Kimberly-Clark


Nitin Besesar


Queen Mgobhozi


Sonali Lal


Shashwat Goyal


Ali Masood


Daigo Ishiyama


Janaína Campoy


Samuel Langat


Alex Njagi


Nabe Amadu Ali


Timothy Kayondo


Eva Mwangi


Tsedey Tamir


Ademola Ajibade


Nicole Andriamampianina


Gabriela Paredes


Camila Cornejo


Susan Rosales


Ana Liliana Silva


Yesica Yau Chen


Vanessa Diaz


Ximena Elias Vargas


Adriana Camacho


Jose David Rojas


Julian Grijalba Facundo

TOILET BOARD COALITION

# វគ្គឆ្នាំ 2025



## 23 ក្រុមហ៊ុន ដែលបានបញ្ចប់វគ្គ

AAP FARM

AAP Farm ផ្តល់ដំណោះស្រាយសម្រាប់គ្រប់គ្រងការកែច្នៃសំណល់ ដោយប្រមូលសំណល់រឹងពីផ្សារទឹកភ្លៀង ដើម្បីចិញ្ចឹមសត្វរុយខ្មៅ (Black Soldier Fly) នៅកសិដ្ឋានរបស់ពួកគេ។ ក្រុមហ៊ុនលក់រុយខ្មៅទាំងនេះទៅអោយ កសិករក្នុងតំបន់ រួមទាំងកសិដ្ឋានមាន់ កសិដ្ឋានត្រី និងកសិដ្ឋានបង្គា។

ECOSTP® sewage to gold™

ECOSTP មានបច្ចេកវិទ្យាកែច្នៃចំហាយទឹកកខ្វក់ 'Net Zero' ដែលមានការចុះបញ្ជីផលិតផល (patented) លើការកែច្នៃទឹកកខ្វក់បែបប្រព័ន្ធវិមជ្ឈការ (decentralised) ហើយប្រព័ន្ធដំណើរការដោយស្វ័យប្រវត្តិ មិនចាំបាច់ប្រើថាមពលអគ្គិសនី គីមី ឬជំនួយពីមនុស្សឡើយ។ បច្ចេកវិទ្យានេះ បានធ្វើការកែច្នៃទឹកកខ្វក់នៅក្នុងប្រព័ន្ធច្រោះបួនស្រទាប់ ដោយការជួយគាំទ្រដោយបាក់តេរីធម្មជាតិ ដើម្បីផលិតទឹកស្អាតសម្រាប់កសិកម្ម និងការដាំបន្លែ។

green lady cambodia

Green Lady Cambodia មានបេសកកម្មក្នុងការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកក្នុងផលិតផលសុខភាពរដូវ ដោយបានណែនាំផលិតផលសុខភាពរដូវដែលអាចបោកទឹក និងប្រើប្រាស់ឡើងវិញបាន។ គម្រោងនេះត្រូវបានគាំទ្រដោយសហការយ៉ាងខ្លាំងជាមួយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចែកចាយផលិតផលទាំងនេះទៅក្មេងស្រីនៅសាលារៀន និងស្ត្រីនៅសហគមន៍ជនបទ។

ilonnati innovations

Ilonnati គឺផ្តល់ដំណោះស្រាយដោយប្រើប្រព័ន្ធ IoT ឆ្លាតវៃសម្រាប់វាស់ និងតាមដានបំពង់បង្ហូរទឹកកខ្វក់ ជាមួយការគាំទ្រសិក្សាពិសេស និងប្រព័ន្ធបញ្ចាក់រូបមន្តទិន្នន័យ ដែលជាតម្រូវការចាំបាច់ដល់ អាជីវកម្មនានា។ គោលបំណងនៃដំណោះស្រាយខាងលើ គឺកាត់បន្ថយចំណាយខ្ពះខ្ជាយលើ ទប់ស្កាត់ការលួច ការជ្រាប ការផ្ទុះបំពង់នៃបំពង់បង្ហូរធំៗ។ ធាតុសំខាន់នៃដំណោះស្រាយនេះរួមមានៈ ស៊ិនស័រឆ្លាតវៃសម្រាប់ការតាមដានយ៉ាងទូលំទូលាយ, បច្ចេកវិទ្យា AI និង ML សម្រាប់ចំណាត់ថ្នាក់ទិន្នន័យ, ការគណនា ដោយប្រើបច្ចេកវិទ្យា Edge Computing សម្រាប់ការឆ្លើយតបពេល ជាក់ស្តែង និងការត្រួតពិនិត្យពី[illegible]។

MILDCARES® Health | Hygiene | Happiness

Mild Cares Pvt Ltd បានបង្កើតអោយដំណោះស្រាយដែលប្រកបដោយ ភាពច្នៃប្រឌិត ក្នុងដោះស្រាយបញ្ហាសុខភាពរដូវនៅតំបន់របស់ពួកគេ តាមរយៈការផ្សព្វផ្សាយ និងអប់រំ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុនក៏លក់ផលិតផល Gynocup ដែលជាកញ្ចប់ផលិតផលសុខភាពរដូវ ហើយបច្ចុប្បន្ន ពួកគេមានអ្នកប្រើប្រាស់ជាង ២០០,០០០នាក់ និងបង្កើតប្រាក់ចំណូលប្រមាណ ១៨០,០០០ ដុល្លារអាមេរិក។

NIRGANDH CLEAN I COMFORTABLE I HEALTHY

Nirgandh ផលិតប្រព័ន្ធបង្គន់មិនចាក់ទឹក (No-Flush) ដែលកែច្នៃកាកសំណល់នៅទីតាំងផ្ទាល់ ហើយ បច្ចេកវិទ្យា Bio-Digestor របស់វាបម្លែងកាកសំណល់ជាទឹក និងឧស្ម័នមេតាន។ ឧស្ម័ននោះឆ្លងកាត់បំពង់ឧស្ម័ន ខណៈដែលទឹកអនាម័យគ្មានមេរោគ ត្រូវបានបម្លែងដោយបាក់តេរីធម្មជាតិ។ ដំណើរការទាំងមូលនេះចំណាយពេលប្រហែល ៨-១០ ថ្ងៃ។

RealRelief

Real Relief គឺជាក្រុមហ៊ុនដែលផលិតក្រណាត់អនាម័យរដូវដែលអាចបោកទឹក ហើយប្រើឡើងវិញបាន។ ចំណុចខុសគ្នារបស់ផលិតផលនេះ គឺមានស្រទាប់ប្រឆាំងមេរោគ (antimicrobial coating) ដែលអាចទប់ស្កាត់មេរោគបាន ទោះបីស្លៀកវាយូរពេលយ៉ាងណាក៏ដោយ ក៏វាមិនបង្កឱ្យមានឆ្លងមេរោគឡើយ។ ដូច្នេះ វាជួយលើកកម្ពស់សុខាភាពអនាម័យរដូវ។

WASTE CHAKRA

Waste Chakra បានអភិវឌ្ឍប្រព័ន្ធកែច្នៃសំណល់មួយ ដែលប្រើបច្ចេកវិទ្យា pyrolysis ដើម្បីបម្លែងកាកមនុស្សជា ធ្យូងអនាម័យ និងបម្លែងទឹកនោមជា struvite និង ammonia តាមរយៈដំណើរការចម្រោះ។

Schedio Scientific

Schedio Scientific គឺជាក្រុមហ៊ុនផ្តល់ដំណោះស្រាយស្វ័យប្រវត្តិកម្ម និងភាពឆ្លាតវៃ ដែលមានគោលបំណងដាក់បញ្ចូលដំណោះស្រាយរបស់ខ្លួនក្នុងវិស័យផ្សេងៗ ជាច្រើន រួមមាន WASH រោងចក្រ ឧស្សាហកម្ម គ្រួសារ និងវិស័យផ្សេងទៀត។

Shapla Wellbeing គឺជាក្រុមហ៊ុនមួយនៅប្រទេសបង់ក្លាដែស ដែលដំឡើងម៉ាស៊ីនដាក់លក់ផលិតផលសុខភាពរដូវ (sanitary pad) ដែលអាចភ្ជាប់ប្រព័ន្ធ IoT បាន ហើយតំឡើងនៅតំបន់សាធារណៈដូចជាស្ថាប័នអប់រំ រោងចក្រ មន្ទីរពេទ្យ និងបង្គន់សាធារណៈ។

SOLINAS

SOLINAS គឺជាក្រុមហ៊ុនដែលផ្តល់ដំណោះស្រាយចល័តជាច្រើន សម្រាប់សម្អាតធុងសេបទិក និងប្រព័ន្ធលូ។ ផលិតផលដំបូងគេរបស់ក្រុមហ៊ុន គឺ Endobot ជារ៉ូបូតដែលប្រើសម្រាប់វិភាគ និងស្វែងការខូចខាតនៅក្នុងបំពង់បង្ហូរ ហើយការជួសជុលទុកជាមុន។ វាគឺត្រូវបានប្រើប្រាស់ជាមួយកម្មវិធីគ្រប់គ្រងបំពង់បង្ហូរ បច្ចេកវិទ្យា Swasth AI។

SUDrain Extending the Life Cycle of Water

SUDrain គឺជាសហគ្រាសសង្គមមួយនៅប្រទេសកម្ពុជា ដែលឈានមុខគេក្នុងការអភិវឌ្ឍដំណោះស្រាយកែច្នៃទឹកកខ្វក់ចីរភាព។ ក្រុមហ៊ុនប្រើបច្ចេក វិទ្យាច្នៃប្រឌិតដ៏ថ្មីមួយ ដែលអនុវត្តតម្រងជីវសាស្ត្រ ផលិតពីស្រកីដូងដែលប្រមូលទិញពីក្នុងស្រុក ដើម្បីកែច្នៃទឹកកខ្វក់អោយទៅជាបរិស្ថានស្អាត។ SUDrain ផ្តល់ដំណោះស្រាយមានតម្លៃសមរម្យ អាចពង្រីកបាន និងមិនចាំបាច់ប្រើអគ្គិសនី ជំនួសប្រព័ន្ធកែច្នៃទឹកកខ្វក់ទូទៅ ក្នុងនោះរួមមានសេវាចាប់ពីការប្រឹក្សា ការរចនា ការដំឡើង រហូតដល់ការថែទាំរយៈពេលវែង។

BSL

Brilliant Sanitation Uganda ជាក្រុមហ៊ុនអនាម័យមួយពីប្រទេសអ៊ូហ្គង់ដា ដែលផ្តល់សេវាសាងសង់បង្គន់អនាម័យ និងធុងសេបទិក សេវាបូមសំអាតលូ និងការផ្តល់សេវាប្រឹក្សាផ្នែកអនាម័យ នៅក្នុងក្រុង Kampala។

KENYA CAST PRODUCTS LTD

Kenya Cast Products ដំឡើងធុងសេបទិកជីវសាស្ត្រប្រភេទមួយទឹក (mono-block) ដែលអាចកែច្នៃទឹកកខ្វក់ (កាកមនុស្ស) នៅតាមតំបន់ផ្ទាល់ ដោយកម្ចាត់មេរោគ និងបាក់តេរីទាំងអស់។ ទឹកចេញពីធុងអាចត្រូវបានកែច្នៃ និងប្រើឡើងវិញ ដើម្បីបង្កើតតំបន់បៃតង។ ក្រុមហ៊ុនផ្តោតលើអតិថិជន ជាលក្ខណៈ គ្រួសារ សាលារៀន និងអាជីវកម្ម។

ecosense SOLUTIONS

Ecosense Solutions (មុននេះហៅថា La Guinéenne de Toilette) គឺជាក្រុមហ៊ុនមួយដែលប្តេជ្ញាក្នុងផ្សព្វផ្សាយ សាងសង់ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអនាម័យទំនើប។ ក្រុមហ៊ុននេះផ្តល់នូវដំណោះស្រាយ និងផលិតផល SATO រួមទាំងបង្គន់ច្នៃប្រឌិត និងប្រព័ន្ធលាងដៃ ដើម្បីបង្កើនសុវត្ថិភាពអនាម័យសម្រាប់សហគមន៍ក្រីក្រងាយរងគ្រោះ រួមមានគ្រួសារចំណូលទាប សាលារៀន និងស្ថាប័នសាធារណៈ។

NHA

NHA គឺជាក្រុមហ៊ុនដំបូងមួយនៅប្រទេសនីហ្សេរ ដែលធ្វើការផ្តល់សេវាបូមសំអាតលូ ដែលបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការកើនឡើងសម្រាប់សេវានេះ។ ក្រុមហ៊ុនមានជំនាញពិសេសក្នុងការប្រមូល និងដឹកជញ្ជូនសំណល់រាវ ការកែច្នៃ និងបង្កើនតម្លៃពីការប្រមូលសំណល់ ព្រមទាំងផ្តល់សេវាកម្ចាត់សត្វល្អិត និងសម្អាត។ លើសពីនេះ NHA ក៏ដំណើរការរោងចក្រកែច្នៃកាកសំណល់អនាម័យ (FSTP) តែមួយគត់នៅទីក្រុង Niamey ផងដែរ។

SIED SARL

SSIED SARL គឺជាក្រុមហ៊ុនមួយដែលបានអភិវឌ្ឍបង្គន់សាធារណៈ SANI SHOP ដែលរចនាឡើងដើម្បីឆ្លើយតបតម្រូវការដែលមានការបែងចែកតាមភេទ។ បរិក្ខារទាំងនេះ គឺរួមបញ្ចូលទាំងធុងអនាម័យសម្រាប់ដាក់កាកសំណល់ នៃផលិតផលសុខភាពរដូវផងដែរ។ ក្រុមហ៊ុននេះ ក៏លើកកម្ពស់ឱកាសការងារដោយមានបុគ្គលិកក្នុងតំបន់ និងគាំទ្រសេដ្ឋកិច្ចក្នុងស្រុកយ៉ាងសកម្ម។

Top

Top Hygienic Products ជាក្រុមហ៊ុនអនាម័យមួយនៅប្រទេសកេនយ៉ា ដែលផ្តល់សេវាបូមលូ សាងសង់បង្គន់អនាម័យ និងគ្រប់គ្រងកាកសំណល់សុខភាពរដូវ ក្នុងតំបន់ Bungama។

akamu ECOSAN

AKAMU ECOSAN ផ្តល់សេវាអនាម័យបៃតង រួមមានបង្គន់ស្ងួត និងតម្រងជីវសាស្ត្រក្នុងការគ្រប់គ្រងកាកសំណល់។

pluvia Cosecha lluvia, mejora tu mundo.

PLUVIA គឺជាអង្គភាពមួយដែលធ្វើ ការប្រមូលផលទឹកភ្លៀង ដែលជាដំណោះស្រាយសាមញ្ញ ប៉ុន្តែមានប្រសិទ្ធភាព និងអាចសម្រួលដល់ការរស់នៅរបស់មនុស្សនៅតំបន់ពួកគេបាន។ បច្ចេកវិទ្យាទាំងនោះ អនុញ្ញាអោយពួកគេប្រមូល និងរក្សាទុកទឹកភ្លៀងបានយ៉ាងមានប្រសិទ្ធភាព និងមានសុវត្ថិភាព។

PROFERT

PROFERT ប្រើបច្ចេកវិទ្យាជីវ ក្នុងការប្រសើរឡើងលើសំណល់សរីរាង្គ និងទឹកកខ្វក់ ដើម្បីអាចប្រើឡើងវិញបាន។

Verde Sostenible

TUKANO ប្រើបច្ចេកវិទ្យាដើម្បីបង្កើនប្រសិទ្ធភាពក្នុងការកែច្នៃទឹកកខ្វក់ និងអនាម័យ។

YAKUFIL Sostenibilidad y Eficiencia

YAKUFIL មានជំនាញពិសេសក្នុងការអភិវឌ្ឍបច្ចេកវិទ្យាបៃតង ដើម្បីគ្រប់គ្រង និងកែច្នៃទឹកកខ្វក់ និងកាក់សំណល់រឹង អោយបានតាមតម្រូវការច្បាប់បរិស្ថាន។

# អំពីព្រឹត្តិការណ៍ និង ការផ្សព្វផ្សាយ 2025

TOILET BOARD COALITION

## ការផ្សព្វផ្សាយ

**20%** ENGAGEMENT RATE

**139K** WEBSITE VIEWS

## ព្រឹត្តិការណ៍

GLOBAL, VIRTUAL

ក្រុមសហគ្រិនសំរាប់ឆ្នាំ២០២៥ កម្មវិធីLIFT-OFF របស់កម្មវិធីពន្លឿនអាជីវកម្ម

ក្រុមសហគ្រិនឆ្នាំ២០២៥ កម្មវិធីបញ្ចប់វគ្គ

PERU & CAMBODIA

2025 WASH Leaders Forum

QUITO, ECUADOR

CLIIQ

MANILA, PHILIPPINES

ADB WATER AND URBAN DEVELOPMENT FORUM

CARTAGENA, COLOMBIA

Funds4impact Summit 2025

DELHI, INDIA

World Toilet Summit

LIMA, PERU

PERÚ SOSTENIBLE

10ma EDICIÓN EXPO AGUA & SOSTENIBILIDAD

2° FORO ECOSANAE Saneamiento & Agua Sostenible

## ឯកសារផ្សេងៗ

**PPP CASE STUDY**
*Cambodia*




**SANITATION X WATER NEXUS**
*Article*




**INVESTMENT PIECE**
*Article*




**Q&A WITH RITESH THAREJA**
*Interview*



# TOILET BOARD COALITION

## របាយការណ៍ប្រចាំឆ្នាំ 2025


www.toiletboard.org
info@toiletboard.org


LinkedIn | WhatsApp | YouTube | Facebook Spanish | Facebook French | Facebook Khmer

សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំរបស់យើង៖

Unilever | Kimberly-Clark | LIXIL | Aqua for All

កម្មវិធីនៅប្រទេសកម្ពុជា ត្រូវបានសហការជាមួយ៖ ADB

កម្មវិធីនៅទ្វីបអាមេរិកឡាទីន ត្រូវបានចូលរួមគាំទ្រដោយ៖ SOURCE OF INNOVATION | IDB | IDB Invest | IDB LAB

កម្មវិធីនៅទ្វីបអាមេរិកឡាទីន ត្រូវបានសហការជាមួយ៖ water for people EVERYONE • FOREVER


The Toilet Board Coalition និងសកម្មភាពរបស់ខ្លួន អាចប្រព្រឹត្តទៅបានដោយសារមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់សមាជិករបស់ខ្លួន។ កម្មវិធីនៅប្រទេសកម្ពុជា គឺត្រូវបានធ្វើការសហការជាមួយ ធនាគារអភិវឌ្ឍន៍អា
ចំណែកឯ កម្មវិធីនៅទ្វីបអាមេរិកឡាទីន គឺមានការចូលរួមគាំទ្រថវិការដោយ IDB និង IDB Lab តាមរយៈ the Source of Innovation alliance និងសហការរៀបចំជាមួយ Water For People។
ខ្លឹមសារខាងលើ គឺជាការទទួលខុសត្រូវរបស់ The Toilet Board Coalition ហើយវាមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់សមាជិក និងដៃគូសហការឡើយ។